**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៧៧៥.....សហវ.ប្រក

# ប្រកាស

***ស្តីពី***

## ការលើកទឹកចិត្តពន្ធបន្ថែមចំពោះការដាំដុះស្រូវ ការប្រមូលទិញស្រូវ និងការផលិតអង្ករនាំចេញ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៩ ចុះថ្ងៃ ទី២០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៩
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ ឲ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរសព្ទ័ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com
Collection by VCAT Professional Consultant

- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម
- បានឃើញប្រកាសលេខ ១០៥៩ សហវ.បក.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់ចំណេញ
- យោងប្រកាសលេខ ៣០៣ សហវ.ពដ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០១ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមលើការនាំចូល និងផ្គត់ផ្គង់ទំនិញមួយចំនួន
- យោងគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០
- យោងការសម្រេចដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១១ លើលិខិតលេខ ៥៨៩៨.សហវ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ របស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមការចាំបាច់នៃការងារ

## សម្រេច

**ប្រការ ១.** ស្របតាមគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្កររបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដាក់ចេញនូវយន្តការលើកទឹកចិត្តពន្ធមួយចំនួនបន្ថែម ចំពោះសហគ្រាសដាំដុះស្រូវ ប្រមូលទិញស្រូវ និងផលិតអង្ករនាំចេញ ដូចខាងក្រោមនេះ ៖

### អាករលើតម្លៃបន្ថែម

១. ការផ្គត់ផ្គង់ស្រូវក្នុងស្រុក ត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រា 0% (សូន្យភាគរយ)

២. ការផ្គត់ផ្គង់អង្ករក្នុងស្រុក ត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រាធម្មតា ១0% (ដប់ភាគរយ)

៣. ការនាំចេញអង្ករ ត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រា 0% (សូន្យភាគរយ)

៤. អាករលើធាតុចូលដែលទាក់ទិននឹងការដាំដុះស្រូវ ប្រមូលទិញស្រូវ និងផលិតអង្ករនាំចេញ ត្រូវបាន អនុញ្ញាតជាឥណទាន ឬបង្វិលសង ។

### ពន្ធលើប្រាក់ចំណេញ និងពន្ធអប្បបរមា

១. សហគ្រាសដាំដុះស្រូវ ប្រមូលទិញស្រូវ និងផលិតអង្ករនាំចេញ ត្រូវទទួលបានការលើកទឹកចិត្ត ៖

ក- លើកលែងពន្ធអប្បរមា ១% (មួយភាគរយ) លើផលរបរប្រចាំឆ្នាំ ។

ខ- រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញជាអតិបរមា ដែលក្នុងនោះមាន ៖ រយៈពេលគន្លឹះ បូករយៈពេល ៣ (បី) ឆ្នាំ បូកនឹងរយៈពេលអាទិភាព ៣ (បី) ឆ្នាំ ។

**រយៈពេលគន្លឹះ ៖** ចាប់ផ្តើមពីការចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារ និងបញ្ចប់នៅចុងក្រោយនៃឆ្នាំសារពើពន្ធណាមួយដែលឆាប់ជាង ៖

- ប្រសិនបើសហគ្រាសមានប្រាក់ចំណេញ គឺឆ្នាំសារពើពន្ធមុនឆ្នាំដែលសហគ្រាសមានប្រាក់ចំណេញដំបូង និង
- ប្រសិនបើសហគ្រាសមានប្រាក់ចំណូល គឺជាឆ្នាំសារពើពន្ធទី៣បន្ទាប់ពីសហគ្រាសទទួលបានប្រាក់ចំណូលដំបូង ។

**រយៈពេល ៣ (បី) ឆ្នាំ ៖** ចាប់ផ្តើមគិតភ្លាមពីឆ្នាំសារពើពន្ធ បន្ទាប់ពីរយៈពេលគន្លឹះ និង២ (ពីរ) ឆ្នាំបន្តបន្ទាប់មកទៀត ។

**រយៈពេលអាទិភាព ៣ (បី) ឆ្នាំ** ៖ ចាប់ផ្តើមគិតភ្លាមបន្ទាប់ពីឆ្នាំសារពើពន្ធទី៣ នៃរយៈពេល៣ (បី) ឆ្នាំ ។

គ- ក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញខាងលើនេះ សហគ្រាសមិនត្រូវបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ១% (មួយភាគរយ) លើផលរបរប្រចាំខែ ។

២. ដើម្បីទទួលបានការលើកទឹកចិត្តអាករលើតម្លៃបន្ថែម ពន្ធលើប្រាក់ចំណេញ និងពន្ធអប្បបរមា ដូចមានចែងខាងលើនេះ សហគ្រាសដាំដុះស្រូវ ប្រមូលទិញស្រូវ និងផលិតអង្ករនាំចេញ ត្រូវស្នើសុំចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារ ។

**ប្រការ ២.** សហគ្រាសដាំដុះស្រូវ ប្រមូលទិញស្រូវ និងផលិតអង្ករនាំចេញ ដែលបានទទួលការលើកទឹកចិត្តដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ ប្រចាំឆ្នាំ និងបង់ពន្ធអាករដទៃទៀតតាមបទប្បញ្ញត្តិស្តីពីសារពើពន្ធជាធរមាន ។ ក្នុងករណីមិនអនុវត្តតាមកាតព្វកិច្ចខាងលើនេះ អគ្គនាយកដ្ឋានពន្ធដារនឹងធ្វើការដកហូតមកវិញនូវការលើកទឹកចិត្ត ដូចមានចែងក្នុងប្រការ១ ។

**ប្រការ ៣.** អគ្គលេខាធិការ នាយកខុទ្ទកាល័យនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ប្រធាននាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសហគ្រាសដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១១

គាត ឈន់

**ចម្លងជូន ៖**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- កាលប្បវត្តិ-ឯកសារ

Collection by VCAT Professional Consultant